ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ០៥០ ដនស/ប្រក/២០២៤

# ប្រកាស

## ស្តីពី

## អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទីទី២៦ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១២ ស្តីពីការបង្កើតនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ២៨៥ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១២០ អនក្រ.បក ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានសម្បទានដីសង្គមកិច្ចចំណុះអគ្គនាយកដ្ឋានលំនៅឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៤៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានកិច្ចការវិវាទដីធ្លីចំណុះអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ២៨៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់
- បានឃើញប្រកាសលេខ០៩៨ ដនស/ប្រក.នីក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាននីមួយៗរបស់មន្ទីរពិសោធន៍ជាតិសំណង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់លក្ខខណ្ឌ និងនីតិវិធី នៃការផ្តល់ ការព្យួរ និងការដកហូត អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ក្នុងគោលដៅអាជីវកម្ម ដើម្បីធានាបាននូវគុណភាព និងសុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងអាយុជីវិតរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន និងធានាគណនេយ្យភាព និងប្រសិទ្ធភាពក្នុងការប្រកបការងារ និងការប្រកបវិជ្ជាជីវៈពាក់ព័ន្ធនឹងការងារពិសោធន៍សំណង់។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះមន្ទីរពិសោធន៍សំណង់ ក្នុងគោលដៅអាជីវកម្មទាំងអស់ដែលអនុវត្តការងារទាំងក្នុងមន្ទីរពិសោធន៍សំណង់ ទាំងនៅតាមការដ្ឋាន។

**ប្រការ៣.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **គ្រឿងផ្គុំសំណង់** សំដៅដល់របនាសម្ព័ន្ធអគាររួមមាន គ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ គ្រឿងផ្គុំដំបូល ជណ្តើរ ជញ្ជាំងរងបន្ទុក និងគ្រឿងផ្គុំសំណង់ផ្សេងៗទៀត ដែលគ្រោងឡើងសម្រាប់ទ្រទម្ងន់។

២- **ច្រកចេញចូលតែមួយ** សំដៅដល់ច្រកចេញចូលតែមួយ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៣- **តំណាងស្របច្បាប់របស់ក្រុមហ៊ុន** សំដៅដល់ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន អគ្គនាយកក្រុមហ៊ុន ឬនាយកក្រុមហ៊ុន ដែលមានគោត្តនាមនិងនាម ត្រូវបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬភ្នាក់ងារតំណាងរបស់ក្រុមហ៊ុនសញ្ជាតិបរទេស ដែលបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ។

៤- **បច្ចេកទេសភូគព្ភសាស្ត្រ** សំដៅដល់ការងារសិក្សាពិសោធន៍ និងវិភាគលើសមាសភាគលក្ខណៈរូប និងមេកានិចរបស់ដី ដើម្បីគណនារកសម្រុត និងលទ្ធភាពទ្រទ្រង់របស់ដី។

៥- **បរិក្ខារសំណង់** សំដៅដល់បរិក្ខារ ដែលត្រូវបានផ្គុំ បង្កើត ឬផលិតឡើង ដើម្បីប្រើប្រាស់ ឬបំពាក់ភ្ជាប់នឹងសំណង់ ដើម្បីបង្កើនគុណភាព ជាសុកភាព និងភាពងាយស្រួល នៃការប្រើប្រាស់សំណង់ មានជាអាទិ៍ អំពូលភ្លើង ខ្សែភ្លើង ខ្សែអុបទិក ឡាវ៉ាបូ រ៉ូប៊ីណេ ជើងម៉ូតទឹក ម៉ាស៊ីនត្រជាក់ ជណ្តើរយន្ត ទុយោ។

៦- **ផលិតផលសំណង់** សំដៅដល់ផលិតផលសម្រេច ឬពាក់កណ្តាលសម្រេច ដែលកើតចេញពីការបង្កើត ឬការផលិតដោយប្រើប្រាស់សម្ភារៈសំណង់ និងសម្រាប់យកទៅប្រើជាគ្រឿងផ្គុំសំណង់ មានជាអាទិ៍ ក្បឿង ឥដ្ឋ បាយអរ បេតុង សសរ ជញ្ជាំង ជហ្វា កម្រាលបេតុង បំពង់លូបេតុង ម្នាងសិលា ស័ង្កសី ស្នាតបត ក្រដាសជញ្ជាំង ថ្នាំលាប ជំរស្មិតការ៉ូ។

៧- **មន្ទីរពិសោធន៍សំណង់** សំដៅដល់ទីកន្លែង ដែលសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ត្រូវបានសិក្សាពិសោធអំពីគុណភាព កម្លាំង ភាពធន់ និងអនុលោមភាពជាមួយបទប្បញ្ញត្តិបច្ចេកទេស ឬស្តង់ដា។

៨- **សម្ភារៈសំណង់** សំដៅដល់វត្ថុធាតុដើមសម្រាប់ធ្វើការលាយ ផ្សំ ផ្គុំ ឬប្រើប្រាស់ជាគ្រឿងផ្គុំសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ មានជាអាទិ៍ ខ្សាច់ ថ្ម ក្រួស ស៊ីម៉ង់ត៍ ដែកកញ្ចក់ ដីឥដ្ឋ សេរ៉ាមិក ឈើ។

៩- **អាជ្ញាបណ្ណ** សំដៅដល់អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅអាជីវកម្ម។

១០- **អ្នកកាន់អាជ្ញាបណ្ណ** សំដៅដល់ក្រុមហ៊ុន ដែលបានទទួលអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី២

## សមត្ថកិច្ច

**ប្រការ៤._**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងលើមន្ទីរពិសោធន៍សំណង់ ក្នុងគោលដៅអាជីវកម្មទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៥._**

លទ្ធផលពិសោធន៍សំណង់ ដែលតម្រូវផ្តល់មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញដោយមន្ទីរពិសោធន៍សំណង់ដែលមានអាជ្ញាបណ្ណ។

## ជំពូកទី៣
## ប្រភេទ នៃអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់

**ប្រការ៦._**

អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ មាន ២ (ពីរ) ប្រភេទដូចខាងក្រោម៖

១- អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ទូទៅ សម្រាប់អនុវត្តការងារពិសោធន៍សំណង់គ្រប់ប្រភេទ។

២- អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ឯកទេស មានដូចខាងក្រោម៖

- ផ្នែកបច្ចេកទេសភូគព្ភសាស្ត្រ
- ផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់
- ផ្នែកគ្រឿងផ្គុំសំណង់។

## ជំពូកទី៤
## លក្ខណៈសម្បត្តិ ដើម្បីទទួលបានអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់

**ប្រការ៧._**

ក្រុមហ៊ុន ដែលអាចទទួលបានអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ទូទៅ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ ១ (មួយ)រូប ជាវិស្វករ ដែលមានមុខជំនាញសំណង់ស៊ីវិល និងដែលមានបទពិសោធន៍ការងារពិសោធន៍សំណង់យ៉ាងតិច ៥ (ប្រាំ)ឆ្នាំ
- មានប្រធានផ្នែកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ ៣ (បី)រូប ជាវិស្វករ ដែលមានមុខជំនាញផ្នែកបច្ចេកទេសភូគព្ភសាស្ត្រ ផ្នែកសំណង់ស៊ីវិល និងផ្នែកមេកានិក ដែលម្នាក់ៗមានបទពិសោធន៍លើការងារជំនាញយ៉ាងតិច ៣ (បី)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ ៣ (បី)រូប ជាវិស្វករ ឬអ្នកបច្ចេកទេសថ្នាក់មធ្យម ដែលមានមុខជំនាញផ្នែកបច្ចេកទេសភូគព្ភសាស្ត្រ ផ្នែកសំណង់ស៊ីវិល និងផ្នែកមេកានិក ក្នុងមួយមុខជំនាញ ១ (មួយ)រូប ដែលម្នាក់ៗមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១ (មួយ)ឆ្នាំ
- មានឧបករណ៍ និងម៉ាស៊ីនពិសោធន៍ស្របតាមស្តង់ដាបច្ចេកទេស ដោយមានលិខិតបញ្ជាក់ពីកម្រិតលម្អៀង និងមានចំនួនគ្រប់គ្រាន់ទៅតាមឯកទេសពិសោធន៍នីមួយៗ។

**ប្រការ៨._**

ក្រុមហ៊ុន ដែលអាចទទួលបានអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ឯកទេស ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ ១ (មួយ)រូប ជាវិស្វករ ដែលមានមុខជំនាញស្របតាមឯកទេសមន្ទីរពិសោធន៍សំណង់ និងដែលមានបទពិសោធន៍ការងារពិសោធន៍សំណង់យ៉ាងតិច ៣ (បី)ឆ្នាំ
- មានប្រធានផ្នែកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ ១ (មួយ)រូប សម្រាប់មួយឯកទេស និងមានមុខជំនាញបច្ចេកទេសស្របតាមឯកទេសមន្ទីរពិសោធន៍សំណង់នោះ ដែលម្នាក់ៗមានបទពិសោធន៍លើការងារជំនាញយ៉ាងតិច ២ (ពីរ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ ១ (មួយ)រូប ជាវិស្វករ ឬអ្នកបច្ចេកទេសថ្នាក់មធ្យមសម្រាប់មួយឯកទេស និងមានមុខជំនាញបច្ចេកទេសស្របតាមឯកទេសមន្ទីរពិសោធន៍សំណង់នោះ ដែលម្នាក់ៗមានបទពិសោធន៍លើការងារជំនាញយ៉ាងតិច ១ (មួយ)ឆ្នាំ
- មានឧបករណ៍ និងម៉ាស៊ីនពិសោធន៍ស្របតាមស្តង់ដាបច្ចេកទេស ដោយមានលិខិតបញ្ជាក់ពីកម្រិតលម្អៀង និងមានចំនួនគ្រប់គ្រាន់ទៅតាមឯកទេសពិសោធន៍នីមួយៗ។

គំរូទម្រង់តារាងឧបករណ៍ និងម៉ាស៊ីនពិសោធន៍សម្រាប់ស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ជាឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

## ជំពូកទី៥

## បែបបទ និងនីតិវិធី នៃការផ្តល់អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់

**ប្រការ៩._**

សំណុំឯកសារស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ មានដូចខាងក្រោម៖

ក. ឯកសារពាក់ព័ន្ធនឹងក្រុមហ៊ុន

| | |
|---|---|
| ១- ពាក្យស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ | ចំនួន១ច្បាប់ |
| ២- ច្បាប់ចម្លងវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | ចំនួន១ច្បាប់ |
| ៣- បញ្ជីរាយនាមនាយកបច្ចេកទេស និងអ្នកបច្ចេកទេស | ចំនួន១ច្បាប់ |

ខ. ឯកសារពាក់ព័ន្ធនឹងអភិបាលរបស់ក្រុមហ៊ុន

| | |
|---|---|
| ១- ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន | ចំនួន១ច្បាប់ |

គ. ឯកសារពាក់ព័ន្ធនឹងនាយកបច្ចេកទេស ប្រធានផ្នែកបច្ចេកទេស និងអ្នកបច្ចេកទេស

| | |
|---|---|
| ១- ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន | ចំនួន១ច្បាប់ |

២- ច្បាប់ចម្លងសញ្ញាបត្រ ឬវិញ្ញាបនបត្របច្ចេកទេស ចំនួន១ច្បាប់

៣- ឯកសារបញ្ជាក់បទពិសោធន៍ការងារ ចំនួន១ច្បាប់

៤- ច្បាប់ចម្លងវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈ ចំនួន១ច្បាប់

គំរូទម្រង់ពាក្យស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ជាឧបសម្ព័ន្ធ២ នៃប្រកាសនេះ។

គំរូទម្រង់បញ្ជីរាយនាមនាយកបច្ចេកទេស ប្រធានផ្នែកបច្ចេកទេស និងអ្នកបច្ចេកទេស ជាឧបសម្ព័ន្ធ៣ នៃប្រកាសនេះ។

**ប្រការ១០._**

រាល់ឯកសារនៅក្នុងសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ត្រូវធ្វើជាភាសាខ្មែរ។

រាល់ឯកសារថតចម្លង មិនតម្រូវឱ្យធ្វើនីត្យានុកូលកម្មឡើយ។

ឯកសារបញ្ជាក់បទពិសោធន៍ការងាររបស់នាយកបច្ចេកទេស ប្រធានផ្នែកបច្ចេកទេស និងអ្នកបច្ចេកទេស ត្រូវបង្ហាញបទពិសោធន៍ពាក់ព័ន្ធនឹងការងារពិសោធន៍សំណង់។

**ប្រការ១១._**

ក្រុមហ៊ុន មានសិទ្ធិចាត់តាំងអ្នកតំណាងផ្សេងទៀត ក្រៅពីតំណាងស្របច្បាប់របស់ក្រុមហ៊ុន ដើម្បីដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ដោយមិនតម្រូវឱ្យមានលិខិតប្រគល់សិទ្ធិឡើយ។

**ប្រការ១២._**

សំណុំឯកសារស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ត្រូវដាក់នៅច្រកចេញចូលតែមួយ។

ក្នុងករណីសំណុំឯកសារស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ មានលក្ខណៈគ្រប់គ្រាន់តាមតារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ច្រកចេញចូលតែមួយត្រូវប្រគល់ច្បាប់ដើមនៃបង្កាន់ដៃទទួលពាក្យស្នើសុំ ជូនទៅម្ចាស់សំណើនៅក្នុងថ្ងៃពិនិត្យសំណុំឯកសារស្នើសុំ និងបន្ទាប់ពីបានបង់កម្រៃសេវាពិនិត្យ និងផ្តល់អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់រួច។

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ មានលក្ខណៈមិនគ្រប់គ្រាន់តាមតារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ច្រកចេញចូលតែមួយត្រូវប្រគល់សំណុំឯកសារស្នើសុំ និងតារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំជូនទៅម្ចាស់សំណើនៅថ្ងៃពិនិត្យសំណុំឯកសារស្នើសុំនោះ។

គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ជាឧបសម្ព័ន្ធ៤ នៃប្រកាសនេះ។

**ប្រការ១៣._**

ការពិនិត្យ និងសម្រេច លើសំណុំឯកសារស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ មានរយៈពេលយ៉ាងយូរ២០ (ម្ភៃ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

**ប្រការ១៤._**

ក្នុងករណីចាំបាច់ មន្ទីរពិសោធន៍ជាតិសំណង់ ត្រូវចាត់មន្ត្រីចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍ និងម៉ាស៊ីនពិសោធន៍ នៅទីតាំងដែលស្នើសុំ។

**ប្រការ១៥._**

ក្នុងករណីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តម្រូវឱ្យកែតម្រូវ ឬបំពេញបន្ថែមសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ច្រកចេញចូលតែមួយ ត្រូវប្រគល់លិខិតជូនដំណឹងស្តីពីការកែតម្រូវ ឬបំពេញបន្ថែមជូនម្ចាស់សំណើ។ ក្រោយពីបានកែតម្រូវ ឬបំពេញបន្ថែមរួច ម្ចាស់សំណើ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការកែតម្រូវ ឬបំពេញបន្ថែមសំណុំឯកសារស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ដោយភ្ជាប់មកជាមួយនូវរាល់ឯកសារ ដែលបានកែតម្រូវ ឬបំពេញបន្ថែម និងយកមកដាក់នៅច្រកចេញចូលតែមួយ។ ច្រកចេញចូលតែមួយ ត្រូវបញ្ជូនឯកសារនេះ ទៅមន្ទីរពិសោធន៍ជាតិសំណង់ ក្នុងថ្ងៃទទួលលិខិតជូនដំណឹងនោះ។

រយៈពេលនៃការកែតម្រូវ ឬបំពេញបន្ថែមសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យ និងសម្រេចផ្តល់អាជ្ញាបណ្ណឡើយ។ ក្នុងករណីមានការកែតម្រូវ ឬបំពេញបន្ថែមសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ រយៈពេលនៃការពិនិត្យ និងសម្រេចផ្តល់អាជ្ញាបណ្ណ ត្រូវចាប់រាប់ឡើងវិញ គិតចាប់ពីថ្ងៃច្រកចេញចូលតែមួយ ចេញបង្កាន់ដៃទទួលសំណុំឯកសារ ដែលបានកែតម្រូវ ឬបំពេញបន្ថែមនោះ។

ក្នុងករណីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបដិសេធផ្តល់អាជ្ញាបណ្ណ ច្រកចេញចូលតែមួយ ត្រូវប្រគល់លិខិតជូនដំណឹង ស្តីពីការបដិសេធផ្តល់អាជ្ញាបណ្ណជូនម្ចាស់សំណើ។

គំរូទម្រង់លិខិតជូនដំណឹង ស្តីពីលទ្ធផលនៃការកែតម្រូវ និង/ ឬបំពេញបន្ថែមសំណុំឯកសារស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ជាឧបសម្ព័ន្ធ៥ នៃប្រកាសនេះ។

គំរូទម្រង់អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ទូទៅ ជាឧបសម្ព័ន្ធ៦ នៃប្រកាសនេះ។

គំរូទម្រង់អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ឯកទេស ជាឧបសម្ព័ន្ធ៧ នៃប្រកាសនេះ។

## ជំពូកទី៦

## សុពលភាព នៃអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់

**ប្រការ១៦._**

អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ មានសុពលភាព ៣ (បី)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ និងអាចបន្តជាថ្មីបាន។

អ្នកកាន់អាជ្ញាបណ្ណ ដែលផុតសុពលភាព អាចបន្តអនុវត្តកាតព្វកិច្ច នៃកិច្ចសន្យាផ្តល់សេវាកម្មពិសោធន៍សំណង់ ដែលត្រូវបានបង្កើតឡើងនៅក្នុងកំលុងពេល ដែលអាជ្ញាបណ្ណនោះ មានសុពលភាព ប៉ុន្តែមិនអាចបង្កើតកិច្ចសន្យាផ្តល់សេវាកម្មថ្មីឡើយ។

**ប្រការ១៧._**

ការដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ត្រូវធ្វើឱ្យបានមុនកាលបរិច្ឆេទផុតសុពលភាពយ៉ាងតិច ៣០ (សាមសិប)ថ្ងៃ។

ការដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ក្រោយកាលបរិច្ឆេទផុតសុពលភាព ត្រូវចាត់ទុកជាការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណថ្មី។

**ប្រការ១៨._**

សំណុំឯកសារស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ មានដូចខាងក្រោម៖

| | |
|---|---|
| ១- ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ | ចំនួន១ច្បាប់ |
| ២- ច្បាប់ថតចម្លងអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ | ចំនួន១ច្បាប់ |
| ៣- ច្បាប់ថតចម្លងរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំចុងក្រោយ | ចំនួន១ច្បាប់ |

ក្នុងករណីមានការប្រែប្រួល ឬការផ្លាស់ប្តូរស្ថានភាពផ្សេងៗ សំណុំឯកសារស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ត្រូវមានបន្ថែមឯកសារដែលពាក់ព័ន្ធ។ បែបបទ នៃការផ្តល់អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបែបបទសម្រាប់ឯកសារបន្ថែមដែលពាក់ព័ន្ធ។

គំរូទម្រង់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ជាឧបសម្ព័ន្ធ៨ នៃប្រកាសនេះ។

គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ជាឧបសម្ព័ន្ធ៩ នៃប្រកាសនេះ។

**ប្រការ១៩._**

បរិបទ នៃការពិនិត្យ និងសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការពិនិត្យ និងសម្រេចលើពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ។

អាជ្ញាបណ្ណ ដែលបន្តសុពលភាពអាជ្ញាបណ្ណមុន ត្រូវរក្សាលេខអាជ្ញាបណ្ណដើម និងត្រូវមានបង្ហាញកាលបរិច្ឆេទ នៃការផ្តល់អាជ្ញាបណ្ណលើកដំបូង និងកាលបរិច្ឆេទ នៃការបន្តសុពលភាពអាជ្ញាបណ្ណលើកចុងក្រោយ។

ការបដិសេធបន្តសុពលភាពអាជ្ញាបណ្ណ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់។

គំរូទម្រង់អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ទូទៅបន្តសុពលភាព ជាឧបសម្ព័ន្ធ១០ នៃប្រកាសនេះ។

គំរូទម្រង់អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ឯកទេសបន្តសុពលភាព ជាឧបសម្ព័ន្ធ១១ នៃប្រកាសនេះ។

## ជំពូកទី៧
## លក្ខខណ្ឌ នៃការអនុវត្តការងាររបស់អ្នកកាន់អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់

**ប្រការ២០.-**

ក្នុងការអនុវត្តការងារមន្ទីរពិសោធន៍សំណង់ អ្នកកាន់អាជ្ញាបណ្ណ ត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

១- ធានាថានាយកបច្ចេកទេស ប្រធានផ្នែកបច្ចេកទេស និងអ្នកបច្ចេកទេសគោរពក្រមសីលធម៌វិជ្ជាជីវៈ ក្នុងពេលអនុវត្តការងារ។

២- ប្រតិបត្តិការងារស្របតាមប្រភេទ នៃអាជ្ញាបណ្ណ។

៣- ប្រតិបត្តិការងារស្របតាមបទដ្ឋានបច្ចេកទេស និងបទប្បញ្ញត្តិបច្ចេកទេសសំណង់។

៤- ផ្ញើរបាយការណ៍បច្ចេកទេសស្តីពីលទ្ធផល នៃការងារពិសោធន៍ដែលខ្លួនបានធ្វើពិសោធ។

៥- អនុវត្តតាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ២១.-**

នាយកបច្ចេកទេសរបស់អ្នកកាន់អាជ្ញាបណ្ណ ត្រូវចុះហត្ថលេខាទទួលខុសត្រូវលើរបាយការណ៍បច្ចេកទេសស្តីពីលទ្ធផល នៃការងារពិសោធន៍សំណង់។

នាយកបច្ចេកទេស ប្រធានផ្នែកបច្ចេកទេស និងអ្នកបច្ចេកទេស នៃអ្នកកាន់អាជ្ញាបណ្ណ ត្រូវចូលរួមកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា ដែលរៀបចំឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការងារបច្ចេកទេស លិខិតបទដ្ឋានគតិយុត្ត និង/ឬបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងការងារពិសោធន៍សំណង់។

## ជំពូកទី៨
## បែបបទសម្រាប់ក្រុមហ៊ុន និងអ្នកវិជ្ជាជីវៈសញ្ជាតិបរទេស

**ប្រការ២២.-**

សម្រាប់ក្រុមហ៊ុនសញ្ជាតិបរទេស ដែលបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ដែលស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតប្រគល់សិទ្ធិជាភ្នាក់ងារតំណាង ដែលចុះហត្ថលេខាដោយប្រធានក្រុមហ៊ុន។

សម្រាប់នាយកបច្ចេកទេស ប្រធានផ្នែកបច្ចេកទេស និងអ្នកបច្ចេកទេសសញ្ជាតិបរទេស សំណុំឯកសារស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ត្រូវមានបន្ថែមបណ្ណការងារ និងឯកសារបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ឯកសារបញ្ជាក់បទពិសោធន៍ការងាររបស់នាយកបច្ចេកទេស ប្រធានផ្នែកបច្ចេកទេស និងអ្នកបច្ចេកទេសសញ្ជាតិបរទេស ត្រូវមានការបញ្ជាក់ទទួលស្គាល់ដោយស្ថានទូត ឬស្ថានតំណាងបរទេសពាក់ព័ន្ធប្រចាំព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៩
## ការព្រមាន ការព្យួរ និងការដកហូតអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់

**ប្រការ២៣._**

នៅពេលទទួលបានព័ត៌មាន ឬពាក្យបណ្ដឹង អំពីការប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌ នៃការអនុវត្តការងារ លិខិតបទដ្ឋានគតិយុត្ត និង/ឬបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងការងារពិសោធន៍សំណង់ មន្ទីរពិសោធន៍ជាតិសំណង់ ត្រូវធ្វើការស៊ើបអង្កេតលើការប្រព្រឹត្តអំពើល្មើសនោះ។

**ប្រការ២៤._**

អ្នកកាន់អាជ្ញាបណ្ណ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរក្នុងករណីមួយ ឬច្រើនដូចខាងក្រោម៖

១- មិនគោរពតាមលក្ខខណ្ឌ នៃការអនុវត្តការងារពិសោធន៍សំណង់ ដូចមានកំណត់ក្នុងប្រការ ២០ នៃប្រកាសនេះ។

២- មិនបានដាក់ពាក្យស្នើសុំប្ដូរនាយកបច្ចេកទេស ប្រធានផ្នែកបច្ចេកទេស ឬអ្នកបច្ចេកទេសដែលបានបាត់បង់នីតិសម្បទា ក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ ដូចមានចែងក្នុងមាត្រា១៦ នៃច្បាប់ស្ដីពីសំណង់។

៣- បានផ្លាស់ប្ដូរនាយកបច្ចេកទេស ប្រធានផ្នែកបច្ចេកទេស ឬអ្នកបច្ចេកទេស ដោយពុំបានជូនដំណឹងមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ២៥._**

លិខិតជូនដំណឹងស្ដីពីការព្រមាន ត្រូវតម្រូវឱ្យអ្នកកាន់អាជ្ញាបណ្ណ ធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃចេញលិខិតជូនដំណឹងស្ដីពីការព្រមាន។

ក្នុងកំលុងពេលដូចមានកំណត់ក្នុងលិខិតជូនដំណឹងស្ដីពីការព្រមាន អ្នកកាន់អាជ្ញាបណ្ណនៅបន្តមានសិទ្ធិចុះកិច្ចសន្យាសេវាកម្មពិសោធន៍សំណង់ថ្មី និងអាចបន្តអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា ដែលត្រូវបានបង្កើតឡើងជាមួយអតិថិជនបាន។

មន្ទីរពិសោធន៍ជាតិសំណង់ ត្រូវអញ្ជើញអ្នកកាន់អាជ្ញាបណ្ណ ដែលទទួលការព្រមានឱ្យទទួលសេចក្ដីជូនដំណឹង ស្ដីពីការព្រមានក្នុងរយៈពេលយ៉ាងយូរ ១ (មួយ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងនោះ។

ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណ បានអនុវត្តរួចរាល់តាមការណែនាំក្នុងលិខិតជូនដំណឹងស្ដីពីការព្រមានក្នុងរយៈពេលកំណត់ អ្នកកាន់អាជ្ញាបណ្ណ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការកែតម្រូវនោះ និងយកមកដាក់នៅច្រកចេញចូលតែមួយជាបន្ទាន់។

គំរូទម្រង់នៃលិខិតជូនដំណឹងស្ដីពីការព្រមានជាឧបសម្ព័ន្ធ១២ នៃប្រកាសនេះ។

គំរូទម្រង់នៃលិខិតជូនដំណឹងស្ដីពីការអនុវត្តតាមការណែនាំក្នុងលិខិតជូនដំណឹងស្ដីពីការព្រមាន ជាឧបសម្ព័ន្ធ១៣ នៃប្រកាសនេះ។

**ប្រការ២៦._**

អាជ្ញាបណ្ណ ត្រូវបានព្យួរមិនលើសពី ៩០ (កៅសិប)ថ្ងៃ ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណ មិនបានអនុវត្តតាមការណែនាំទាន់ពេលវេលាដូចមានចែងក្នុងប្រការ២៦។

លិខិតជូនដំណឹង ស្ដីពីការព្យួរអាជ្ញាបណ្ណ ត្រូវណែនាំអ្នកកាន់អាជ្ញាបណ្ណ ឱ្យធ្វើការកែតម្រូវក្នុងរយៈពេល នៃការព្យួរ គិតចាប់ពីថ្ងៃចេញលិខិតជូនដំណឹងស្ដីពីការព្យួរ។

ក្នុងកំលុងពេលអាជ្ញាបណ្ណត្រូវបានព្យួរ អ្នកកាន់អាជ្ញាបណ្ណមិនអាចចុះកិច្ចសន្យាថ្មីឡើយ ប៉ុន្តែអាចបន្តអនុវត្តកាតព្វកិច្ច នៃកិច្ចសន្យាដែលត្រូវបានបង្កើតឡើងជាមួយអតិថិជនបាន។

សេចក្ដីជូនដំណឹង ស្ដីពីការព្យួរអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ត្រូវផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយ ដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មាន។

គំរូទម្រង់នៃលិខិតជូនដំណឹងស្ដីពីការព្យួរអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ជាឧបសម្ព័ន្ធ១៤ នៃប្រកាសនេះ។

គំរូទម្រង់នៃលិខិតជូនដំណឹងស្ដីពីការអនុវត្តតាមការណែនាំក្នុងលិខិតជូនដំណឹងស្ដីពីការព្យួរអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ជាឧបសម្ព័ន្ធ១៥ នៃប្រកាសនេះ។

**ប្រការ២៧._**

ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណអនុវត្តទាន់ពេលវេលា តាមការណែនាំក្នុងលិខិតជូនដំណឹង ស្ដីពីការព្យួរ អ្នកកាន់អាជ្ញាបណ្ណ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការកែតម្រូវនោះ និងយកមកដាក់នៅច្រកចេញចូលតែមួយជាបន្ទាន់។ មន្ទីរពិសោធន៍ជាតិសំណង់ ត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីសម្រេចលុបចោលការព្យួរអាជ្ញាបណ្ណ។

**ប្រការ២៨._**

អាជ្ញាបណ្ណ ត្រូវបានដកហូត ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណស្ថិតក្នុងស្ថានភាព ឬប្រព្រឹត្តអំពើមួយ ឬច្រើនដូចខាងក្រោមៈ

១- បាត់បង់នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងវិស័យសំណង់ដូចមានចែងក្នុងមាត្រា១៦ និងមាត្រា១៨ នៃច្បាប់ស្ដីពីសំណង់។

២- មិនគោរពតាមលក្ខខណ្ឌ នៃការអនុវត្តការងារពិសោធន៍សំណង់ ដូចមានកំណត់ក្នុងប្រការ២០ នៃប្រកាសនេះ។

៣- មិនបានអនុវត្តតាមការណែនាំទាន់ពេលវេលា ដូចមានកំណត់ក្នុងលិខិតជូនដំណឹងស្ដីពីការព្យួរអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់។

**ប្រការ២៩._**

ក្នុងករណីមន្ទីរពិសោធន៍ជាតិសំណង់ ទទួលបានព័ត៌មានអំពីអំពើល្មើស ដែលអាចជាមូលហេតុ នៃការដកហូតអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ មន្ទីរពិសោធន៍ជាតិសំណង់ ត្រូវសុំគោលការណ៍ចាត់មន្ត្រីដើម្បីធ្វើការសាកសួរ ប្រមូលព័ត៌មាន និងធ្វើរបាយការណ៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងលើកសំណើដកហូតអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ជាយថាហេតុ។

ក្នុងករណីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចដកហូតអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ មន្ទីរពិសោធន៍ជាតិសំណង់ ត្រូវអញ្ជើញអ្នកកាន់អាជ្ញាបណ្ណមកទទួលយកលិខិតជូនដំណឹង ស្ដីពីការដកហូតអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ក្នុងរយៈពេលយ៉ាងយូរ ១ (មួយ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងនោះ។

អាជ្ញាបណ្ណដែលត្រូវបានដកហូត មិនអាចត្រូវបានផ្ដល់ជូនឡើងវិញ ឬធ្វើនិយ័តកម្មឡើយ។

លិខិតជូនដំណឹង ស្ដីពីការដកហូតអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ត្រូវផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយដែលក្រសួងមាន។

ក្រោយពេលអាជ្ញាបណ្ណ ត្រូវបានដកហូត អ្នកកាន់អាជ្ញាបណ្ណ មិនអាចបន្តអនុវត្តកាតព្វកិច្ច នៃកិច្ចសន្យាផ្ដល់សេវាកម្មពិសោធន៍សំណង់ ដែលត្រូវបានបង្កើតឡើងជាមួយអតិថិជនបានឡើយ។ ក្នុងករណីនេះ អតិថិជនមានសិទ្ធិរំលាយកិច្ចសន្យាដោយឯកតោភាគី និងមានសិទ្ធិទាមទារសំណងការខូចខាតបង្កឡើងដោយអ្នកកាន់អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់។

គំរូទម្រង់លិខិតជូនដំណឹងស្ដីពីការដកហូតអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ជាឧបសម្ព័ន្ធ១៦ នៃប្រកាសនេះ។

## ជំពូកទី១០

## អន្តរប្បញ្ញត្តិ

**ប្រការ៣០._**

មន្ទីរពិសោធន៍សំណង់ ដែលផ្ដល់សេវាពិសោធន៍ មុនប្រកាសនេះចូលជាធរមាន ត្រូវស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់តាមលក្ខខណ្ឌ និងនិតិវិធី ដូចមានចែងក្នុងប្រកាសនេះ។

## ជំពូកទី១១

## ការប្ដឹងតវ៉ា

**ប្រការ៣១._**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការផ្ដល់អាជ្ញាបណ្ណ ឬដកហូតអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ មានសិទ្ធិប្ដឹងតវ៉ាទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬទៅតុលាការ តាមនីតិវិធីជាធរមាន។

## ជំពូកទី១២

## អវសានប្បញ្ញត្តិ

**ប្រការ៣២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣៣._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៥រោច ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
  “**ដើម្បីជូនជ្រាប**”
- ដូចប្រការ៣៣ “**ដើម្បីអនុវត្ត**”
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១ នៃប្រកាសលេខ០៥០ ដនសា/ប្រក/មហាងស ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២៦

**ស្ដីពីអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់**

*គំរូទម្រង់តារាងឧបករណ៍ និងម៉ាស៊ីនពិសោធន៍សម្រាប់ស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់*

**ឧបករណ៍ និងម៉ាស៊ីនពិសោធន៍សម្រាប់ស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់**

| ល.រ | ឈ្មោះឧបករណ៍ និងម៉ាស៊ីនពិសោធន៍ | ចំនួន | ផ្សេងៗ |
|---|---|---|---|
| **១. ផ្នែកពិសោធន៍បច្ចេកទេសភូគព្ភសាស្ត្រ** | | | |
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |
| | | | |
| | | | |
| | | | |
| **២. ផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់** | | | |
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |
| | | | |
| | | | |
| | | | |

| | | | |
|---|---|---|---|
| **៣. ផ្នែកគ្រឿងផ្ទិសំណង់សំណង់** | | | |
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |
| | | | |
| | | | |
| | | | |

| | | | |
|---|---|---|---|
| **៤. ផ្នែកឧបករណ៍ និងគ្រឿងចក្រសំណង់** | | | |
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |
| | | | |
| | | | |
| | | | |

ឧបសម្ព័ន្ធ២ នៃប្រកាសលេខ០៥០ ដនសា/ប្រក/២៣២៥ ចុះថ្ងៃទី០៥ ខែ មិថុនា ឆ្នាំ២០២៦

**ស្តីពីអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់**

*គំរូទម្រង់ពាក្យស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៚៙

**រូបសញ្ញា**
**និងនាមករណ៍**
**ក្រុមហ៊ុន**

ថ្ងៃ ________ ខែ ______ ឆ្នាំ____________ព.ស. ______

______________ ថ្ងៃទី_____ខែ_______ ឆ្នាំ _______

**ពាក្យស្នើសុំអាជ្ញាមន្ទីរពិសោធន៍សំណង់ ប្រភេទ** _________

នាមករណ៍ក្រុមហ៊ុន ______________________________________________

លេខចុះបញ្ជីពាណិជ្ជកម្ម ____________________ ចុះថ្ងៃទី _____ ខែ ________ ឆ្នាំ ________

ទីស្នាក់ការ ផ្ទះលេខ________ ផ្លូវ _________ ភូមិ _____________ ឃុំ/ សង្កាត់ ___________

ក្រុង/ ស្រុក/ ខណ្ឌ _________________________ រាជធានី/ ខេត្ត ______________________

លេខទូរសព្ទក្រុមហ៊ុន ____________________________________________

គោត្តនាមនិងនាមអ្នកតំណាង ______________________________________

អត្តសញ្ញាណបណ្ណ/ លិខិតឆ្លងដែនលេខ _________________________________

ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ________ ផ្លូវ _________ ភូមិ ___________ ឃុំ/ សង្កាត់ ___________

ក្រុង/ ស្រុក/ ខណ្ឌ _________________________ រាជធានី/ ខេត្ត ______________________

លេខទូរសព្ទ ___________________________________________________

ស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ ប្រភេទ ___________________________

ផ្នែក _________________________________________________________

យើងខ្ញុំសូមសន្យាប្រកបអាជីវកម្មមន្ទីរពិសោធន៍សំណង់ ដោយគោរពច្បាប់ បទដ្ឋានគតិយុត្ត បទប្បញ្ញត្តិបច្ចេកទេស និងគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ហត្ថលេខានិងឈ្មោះតំណាងនិងត្រារបស់ក្រុមហ៊ុន**

ឧបសម្ព័ន្ធ៣ នៃប្រកាសលេខ ០៤០ វិនស/ប្រក/២០២៦ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០២៦

**ស្តីពីអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់**

*គំរូទម្រង់បញ្ជីរាយនាមនាយកបច្ចេកទេស ប្រធានផ្នែកបច្ចេកទេស និងអ្នកបច្ចេកទេស*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៖៧

**រូបសញ្ញា**
**និងនាមករណ៍**
**ក្រុមហ៊ុន**

ថ្ងៃ ______________ ខែ _______ ឆ្នាំ_______ព. ស. _______

ធ្វើនៅ _______________ថ្ងៃទី_____ខែ________ឆ្នាំ ________

នាមករណ៍ក្រុមហ៊ុន ________________________________________________________________

លេខចុះបញ្ជីពាណិជ្ជកម្ម ____________________________ ចុះថ្ងៃទី _____ ខែ ________ ឆ្នាំ ________

លេខទូរសព្ទ __________________________________________________________________

**បញ្ជីរាយនាមនាយកបច្ចេកទេស ប្រធានផ្នែកបច្ចេកទេស និងអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន**

| ល.រ | គោត្តនាមនិងនាម | ភេទ | តួនាទី | សញ្ញាបត្រ | មុខជំនាញ | បទពិសោធន៍ |
|---|---|---|---|---|---|---|
| ១ | | | នាយកបច្ចេកទេស | | | ឆ្នាំ |
| ២ | | | ប្រធានផ្នែកបច្ចេកទេស | | | ឆ្នាំ |
| ៣ | | | ប្រធានផ្នែកបច្ចេកទេស | | | ឆ្នាំ |
| ៤ | | | ប្រធានផ្នែកបច្ចេកទេស | | | ឆ្នាំ |
| ៥ | | | អ្នកបច្ចេកទេស | | | ឆ្នាំ |
| ៦ | | | អ្នកបច្ចេកទេស | | | ឆ្នាំ |
| ៧ | | | អ្នកបច្ចេកទេស | | | ឆ្នាំ |
| ៨ | | | អ្នកបច្ចេកទេស | | | ឆ្នាំ |
| ៩ | | | អ្នកបច្ចេកទេស | | | ឆ្នាំ |
| ១០ | | | អ្នកបច្ចេកទេស | | | ឆ្នាំ |

ខ្ញុំបាទ/នាងខ្ញុំសូមអះអាងចំពោះមុខច្បាប់ថាព័ត៌មានខាងលើជាការពិតទាំងអស់។

**ហត្ថលេខានិងឈ្មោះតំណាងនិងត្រារបស់ក្រុមហ៊ុន**

ឧបសម្ព័ន្ធ៤ នៃប្រកាសលេខ ០៥០ ដនស/ប្រក/មគដស ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៦

**ស្តីពីអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់**

*គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**អគ្គនាយកដ្ឋានរដ្ឋបាល**
**ច្រកចេញចូលតែមួយ**

**តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណពិសោធន៍សំណង់ ប្រភេទ ________**

នាមករណ៍ក្រុមហ៊ុន ____________________________________________

លេខទូរសព្ទ ____________________________________________

| ល.រ. | រាយឈ្មោះឯកសារ | ចំនួនតម្រូវ | ចំនួនទទួល | ភាពមិនត្រឹមត្រូវផ្នែកទម្រង់ |
|---|---|---|---|---|
| ក. | **ឯកសារពាក់ព័ន្ធនឹងក្រុមហ៊ុន** | | | |
| ១ | ពាក្យស្នើសុំអាជ្ញាបណ្ណ | ១ | | |
| ២ | ច្បាប់ថតចម្លងវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | ១ | | |
| ៣ | បញ្ជីរាយនាមនាយកបច្ចេកទេសនិងអ្នកបច្ចេកទេស | ១ | | |
| ខ. | **ឯកសារពាក់ព័ន្ធនឹងអភិបាលក្រុមហ៊ុន** | | | |
| ១ | ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ | ១ | | |
| | ច្បាប់ថតចម្លងលិខិតឆ្លងដែន និងទិដ្ឋាការ | ១ | | |
| គ. | **ឯកសារពាក់ព័ន្ធនឹងនាយកបច្ចេកទេស** | | | |
| ១ | ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ | ១ | | |
| | ច្បាប់ថតចម្លងលិខិតឆ្លងដែន និងទិដ្ឋាការ | ១ | | |
| ២ | ច្បាប់ថតចម្លងសញ្ញាបត្រ | ១ | | |
| ៣ | ឯកសារបញ្ជាក់បទពិសោធន៍ការងារ | ១ | | |
| ៤ | ច្បាប់ថតចម្លងវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈ | ១ | | |
| ៥ | បណ្ណការងារ ក្នុងករណីអ្នកវិជ្ជាជីវៈសញ្ជាតិបរទេស | ១ | | |
| ៦ | ច្បាប់ថតចម្លងឯកសារបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីអ្នកវិជ្ជាជីវៈសញ្ជាតិបរទេស | ១ | | |

| | | | | |
|---|---|---|---|---|
| **ឃ.** | **ឯកសារពាក់ព័ន្ធនឹងប្រធានផ្នែកបច្ចេកទេស** | | | |
| **ឃ.១** | **ប្រធានផ្នែកបច្ចេកទេស ផ្នែកបច្ចេកទេសត្បូងពូលសាស្ត្រ** | | | |
| ១ | ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ | ១ | | |
| | ច្បាប់ថតចម្លងលិខិតឆ្លងដែន និងទិដ្ឋាការ | ១ | | |
| ២ | ច្បាប់ថតចម្លងសញ្ញាបត្រ | ១ | | |
| ៣ | ឯកសារបញ្ជាក់បទពិសោធន៍ការងារ | ១ | | |
| ៤ | ច្បាប់ថតចម្លងវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈ | ១ | | |
| ៥ | បណ្ណការងារ ក្នុងករណីអ្នកវិជ្ជាជីវៈសញ្ជាតិបរទេស | ១ | | |
| ៦ | ច្បាប់ថតចម្លងឯកសារបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីអ្នកវិជ្ជាជីវៈសញ្ជាតិបរទេស | ១ | | |
| **ឃ.២** | **ប្រធានផ្នែកបច្ចេកទេស ផ្នែកសំណង់ស៊ីវិល** | | | |
